ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ០៧ សរ.

# សារាចរ
# ស្តីពី
# វិធានការត្រួតពិនិត្យនិងទប់ស្កាត់ការឆ្លងរាលដាលជំងឺផ្តាសាយបក្សី

រហូតមកដល់បច្ចុប្បន្ននេះ ជំងឺផ្តាសាយបក្សីនៅតែកំពុងបន្តកើតមានឡើងនៅបណ្តាប្រទេសមួយចំនួនក្នុងតំបន់និងពិភពលោក។ ដោយឡែក នៅប្រទេសកម្ពុជា ក្នុងរយៈពេលពីរខែដើមឆ្នាំ២០១៣នេះ ជំងឺផ្តាសាយបក្សី H5N1 បានផ្ទុះ និងចម្លងទៅមនុស្សចំនួន៩នាក់ ក្នុងនោះមនុស្សបានស្លាប់ចំនួន៨នាក់ ហើយគិតតាំងពីឆ្នាំ២០០៥មក មានមនុស្សឈឺចំនួន៣០នាក់ និងស្លាប់ចំនួន២៧នាក់ ដោយសារជំងឺនេះ។

រាជរដ្ឋាភិបាលបានសង្កេតឃើញថា ទោះបីមានការចាត់វិធានការទប់ស្កាត់ដោយស្ថាប័នជំនាញក្តី ក៏ស្ថានភាពនៃការរាតត្បាត និងអត្រាមនុស្សស្លាប់ដោយជំងឺផ្តាសាយបក្សីមានកម្រិតគួរឱ្យបារម្ភ។ ដូចនេះ ក្នុងគោលបំណងធានាបាននូវសុវត្ថិភាពជូនប្រជាពលរដ្ឋឱ្យកាន់តែមានប្រសិទ្ធភាព រាជរដ្ឋាភិបាលសូមធ្វើការណែនាំដល់ក្រសួង ស្ថាប័នពាក់ព័ន្ធដូចខាងក្រោម÷

១. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបន្តជំរុញការអនុវត្តវិធានការចាំបាច់ និងបន្ទាន់នានា ដើម្បីបង្ការ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺផ្តាសាយបក្សី ដោយត្រូវធ្វើការតាមដាន ស្រាវជ្រាវយ៉ាងម៉ត់ចត់ និងជាប្រចាំលើសុខភាពបក្សីនៅទូទាំងប្រទេស និងត្រូវអនុវត្តវិធានជីវសុវត្ថិភាព វិធានអនាម័យនៅគ្រប់ទីកន្លែងចិញ្ចឹមបក្សី កន្លែងប្រមូលផ្តុំបក្សី និងទីផ្សារបក្សី។ ជាមួយនេះ ក៏ត្រូវពង្រឹងការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលសត្វ ព្រមទាំងធ្វើការផ្សព្វផ្សាយទូលំទូលាយតាមគ្រប់រូបភាពដល់ប្រជាពលរដ្ឋឱ្យបានយល់ដឹងអំពីជំងឺផ្តាសាយបក្សី និងចូលរួមអនុវត្តវិធានការការពារ។

២. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសុខាភិបាល ត្រូវបន្តពង្រឹងកិច្ចសហការគ្នាក្នុងការផ្តល់ព័ត៌មានឱ្យបានទាន់ពេលវេលា សំដៅចាត់វិធានការទប់ស្កាត់ការឆ្លងរាលដាល និងលុបបំបាត់ជំងឺផ្តាសាយបក្សី។

៣. ក្រសួងមហាផ្ទៃ ត្រូវណែនាំដល់អភិបាលនៃគណៈអភិបាលរាជធានី ខេត្តឱ្យចាត់វិធានការបន្ទាន់ និង

ម៉ឺងម៉ាត់ក្នុងការទប់ស្កាត់ឱ្យបាននូវការធ្វើចរាចរបក្សី និងផលិតផលមានដើមកំណើតពីបក្សីដែលខុសច្បាប់តាមគ្រប់រូបភាព និងគ្រប់ច្រកទាំងអស់។

៤. អាជ្ញាធរមូលដ្ឋានត្រូវ សហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការត្រួតពិនិត្យ និងគ្រប់គ្រងសត្តឃាតដ្ឋាន និងកន្លែងពិឃាត តាមស្មារតីនៃអនុក្រឹត្យលេខ១០៨អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ។

៥. ក្រសួង ស្ថាប័នពាក់ព័ន្ធ កងរាជអាវុធហត្ថលើផ្ទៃប្រទេស អគ្គស្នងការនគរបាលជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបង្កើនកិច្ចសហការ និងចូលរួមយ៉ាងសកម្មជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសុខាភិបាលក្នុងការអនុវត្តវិធានការទប់ស្កាត់ជំងឺផ្តាសាយបក្សីឱ្យទទួលបានជោគជ័យ។

ទទួលបាននូវសារាចរនេះ ក្រសួងមហាផ្ទៃ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសុខាភិបាល ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តសារាចរនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

__កន្លែងទទួល__

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ